32/4

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌ
លេខ: ២៦០ "ឧ១"ក្រ១០
ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២១
-សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៣៥៥៣
ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២០
-សំណុំរឿងស៊ើបសួរ
លេខ: ២៤១២
ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០
-សំណុំរឿងជំនុំជម្រះ
លេខ: ៣៨៨៦
ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២០

## គោរនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២១ វេលាម៉ោង ០៨ និង ០០ នាទី ព្រឹក នៅសាលសវនាការទី ៩ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា
-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

### មេធាវីការពារឱ្យជនជាប់ចោទ

-លោក [redacted] សុខន្ធា អត្តលេខ ១៥៣៩ និងលោកស្រី [redacted] រិសី អត្តលេខ ៩៧៥។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៥៣ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២០ ដែលមានជនជាប់ចោទ៖

- ឈ្មោះ [redacted] ស្រីនិត ហៅ ណុច ភេទស្រី អាយុ ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្ដី ឈ្មោះ [redacted] (លែងលះ) មានកូនចំនួន ០៥ នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ- PJ)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៩៤០ "ណ" ដ.ឃ.ដ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០។

ជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច តាមបណ្ដោយផ្លូវលេខ ៧៩ អិមស៊ី ក្បែរផ្សារពោធិ៍ញាណ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិ មាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

### <u>អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ</u>

កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ១៥ និង ១៥នាទី កម្លាំងការិយាល័យស៊ើបការខាងក្រៅ នៃមន្ទីរប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបជាក់ស្ដែង នៅចំណុចតាមបណ្ដោយផ្លូវលេខ ៧៩ អិមស៊ី ក្បែរផ្សារពោធិ៍ញាណ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដោយឃាត់ខ្លួនបានជនជាប់ចោទឈ្មោះ [redacted] ស្រីនិត រួមនឹងវត្ថុតាងជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ICE ចំនួន ០១ កញ្ចប់ ទម្ងន់ ៤៨.៧៨ g (សែសិបប្រាំបី កណ្ដក់សញ្ញាចិតសិបប្រាំបី ក្រាម) ដែលជនជាប់ចោទកំពុងធ្វើសកម្មភាពលក់ចែកចាយគ្រឿងញៀននោះ។ បន្ទាប់មក សមត្ថកិច្ចបាននាំខ្លួនជនជាប់ចោទទៅសាកសួរ ហើយជនជាប់ចោទបានឆ្លើយថា គ្រឿងញៀននោះ ខ្លួនបានទិញពីឈ្មោះ នាង ភេទប្រុស អាយុប្រហែល ២៥ឆ្នាំ ដែលមានទូរស័ព្ទលេខ ០៨៦ ៩៤ ៧៦ ៧២។

បានឃើញរបាយការណ៍លេខ ៦៤២ រ.ប.ក ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២០ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃក្រសួងមហាផ្ទៃ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៥៤៦ អ.យ.ណ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៦២ អ.យ.ណ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៤៧៣ "ណ" ដ.ដ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ហៅ ណុច បានឆ្លើយ៖ ខ្ញុំបានស្គាល់ឈ្មោះ នាង នៅកំលុងខែមេសា ឆ្នាំ ២០២០ ដោយខ្ញុំបានស្គាល់គាត់តាមរយៈហ្វេសប៊ុកឈ្មោះ Ah Vet ហើយខ្ញុំក៏បានទៅរស់នៅជាមួយគាត់នៅកំលុងខែឧសភា ឆ្នាំ២០២០។ ពេលខ្ញុំទៅរស់នៅជាមួយគាត់នៅក្នុងផ្ទះសំណាក់ ហេង រស្មី ក្បែរស្ថានីយ៍បូមទឹក បឹងទំពុន ទើបខ្ញុំដឹងថា គាត់ជាអ្នកលក់គ្រឿងញៀន ដោយខ្ញុំធ្លាប់ឃើញគាត់ទំនាក់ទំនងទិញគ្រឿងញៀន ប៉ុន្តែមិនដឹងថា ទម្ងន់ និងតម្លៃប៉ុន្មាននោះទេ ដោយគ្រាន់តែខ្ញុំដឹងថា គាត់ទិញគ្រឿងញៀននោះដើម្បីយកមកវេចកលក់បន្តជាកញ្ចប់តូចៗក្នុងតម្លៃ ២០,០០០៛ (ពីរម៉ឺនរៀល) ហើយខ្ញុំមិនដែលយកគ្រឿងញៀនទៅឲ្យអ្នកណានោះទេ។ ខ្ញុំធ្លាប់ឃើញមានគេមកទិញគ្រឿងញៀនពីគាត់នៅក្បែរផ្ទះសំណាក់ដែលពួកខ្ញុំស្នាក់នៅនោះ ក្នុងមួយថ្ងៃចំនួន ០៣ ទៅ ០៤ លើក។ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ពេលយប់ គាត់បានប្រាប់ខ្ញុំថា មិនបាច់ទៅធ្វើការទេ ចាំគាត់ឲ្យប្រាក់ខ្ញុំចាយ ហើយឲ្យខ្ញុំទៅយកប្រាក់ចំនួន ៦០០$ (ប្រាំមួយរយដុល្លារអាមេរិក) ពីគេនៅមុខក្លោងទ្វារវត្តពោធិ៍ញាណ ដោយមិនបានប្រាប់ខ្ញុំថា ប្រាក់នោះជាចំណូលពីអ្វីនោះទេ។ ខ្ញុំបានជិះម៉ូតូកង់បីឥណ្ឌាទៅម្នាក់ឯងទៅទីនោះ ឯគាត់ជិះម៉ូតូជាមួយមនុស្សប្រុសម្នាក់ទៀតដែលខ្ញុំមិនធ្លាប់ស្គាល់នោះទេ។ ពេលខ្ញុំទៅដល់ ខ្ញុំកំពុងតែទទួលប្រាក់ពីគេ ស្រាប់តែមានសមត្ថកិច្ចមកដល់ចាប់ឃាត់ខ្លួនខ្ញុំ ចំណែកឈ្មោះ នាង បានជិះម៉ូតូរត់គេចខ្លួនបាត់តែម្តង។ គ្រឿងញៀនដែលសមត្ថកិច្ចរកឃើញនោះ មិនមែនជារបស់ខ្ញុំនោះទេ គឺជារបស់ឈ្មោះ នាង ហើយខ្ញុំមិនដែលជក់ និងលក់គ្រឿងញៀននោះឡើយ។

## សេចក្តីសន្និដ្ឋានរឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់, ស្តាប់ចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងរួចមក ដូចនេះ តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ហៅ ណុច ភេទស្រី អាយុ ២១ឆ្នាំ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។ ដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៦២ អ.យ.ណ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០២០ ទុកជាបានការដដែល។ សូមតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

មេធាវីបានធ្វើការសន្និដ្ឋានថា៖ តាមចម្លើយរបស់កូនក្តីខ្លួនបានបង្ហាញឲ្យឃើញថា កូនក្តីខ្លួនទទួលស្គាល់ចម្លើយមួយផ្នែកដែលបានឆ្លើយនៅអយ្យការប៉ុណ្ណោះ ព្រោះនៅថ្ងៃកើតហេតុ ពេលដែលឈ្មោះ នាង ឲ្យកូនក្តីខ្លួនទៅយកប្រាក់ចំនួន ៦០០$ (ប្រាំមួយរយដុល្លារអាមេរិក) នោះ គឺមិនបានប្រាប់ថា ប្រាក់នោះជាចំណូលមកពីប្រភពណាឡើយ។ កូនក្តីខ្លួនធ្លាប់មានបញ្ហាបែកបាក់គ្រួសារ និងមានការខ្វះខាតប្រាក់ក្នុងការចិញ្ចឹមកូនចំនួន ០៥ នាក់ ដែលមាននៅក្នុងបន្ទុក ទើបកូនក្តីខ្លួនសម្រេចចិត្តធ្វើតាមការបញ្ជារបស់ឈ្មោះ នាង ដើម្បីទទួលបានកម្រៃខ្លះ ទាំងមិនដឹងថា ការធ្វើបែបនោះបានធ្វើឲ្យ

ពាក់ព័ន្ធជាមួយបទល្មើសឡើយ។ ម្យ៉ាងទៀត គ្រឿងញៀនដែលសមត្ថកិច្ចរកឃើញនោះក៏មិនមែនជារបស់កូនក្តីខ្លួនដែរ។ ហេតុនេះ សូមតុលាការមេត្តាសម្រេចផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនផង។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ហៅ ណុច បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សូមឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យរូបខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>សំអាងហេតុ</u>

- ពិតជាមានអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច តាមបណ្តោយផ្លូវលេខ ៧៩ អឹម ស៊ុ ក្បែរផ្សារពោធិ៍ញាណ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ហៅ ណុច ភេទស្រី អាយុ ២១ឆ្នាំ ពិតប្រាកដមែន ។

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ហៅ ណុច ឃើញថា៖ ជនជាប់ចោទបានទៅរស់នៅជាមួយឈ្មោះ នាង និងបានដឹងថាឈ្មោះ នាង ជាអ្នកជួញដូរគ្រឿងញៀន ហើយជនជាប់ចោទក៏នៅតែរស់នៅជាមួយឈ្មោះ នាង ដដែល។ ម្យ៉ាងទៀត ជនជាប់ចោទក៏ធ្លាប់បានឃើញឈ្មោះ នាង ធ្វើការជួញដូរគ្រឿងញៀន ប៉ុន្តែមិនបានរាយការណ៍ទៅដល់សមត្ថកិច្ចនោះទេ ដែលទង្វើនេះបានបង្ហាញពីចេតនាក្នុងការលាក់កំបាំង និងការចូលរួមប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទជាមួយឈ្មោះ នាង រួចទៅហើយ។ ត្បិតតែ ជនជាប់ចោទបានឆ្លើយបដិសេធថា គ្រឿងញៀននោះមិនមែនជារបស់ខ្លួនក្តី ប៉ុន្តែនៅថ្ងៃកើតហេតុ ជនជាប់ចោទពិតជាបានទៅទទួលយកប្រាក់ ដែលមានប្រភពពីការជួញដូរគ្រឿងញៀនតាមបញ្ជារបស់ឈ្មោះ នាង ហើយក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនប្រាកដមែន។ ហេតុនេះ ការឆ្លើយបដិសេធរបស់ជនជាប់ចោទ គឺគ្រាន់តែជាចម្លើយដោះបន្ទុក ដោយគ្មានភស្តុតាង ឬសាក្សីណាមួយអាចមកបញ្ជាក់បានថា ជនជាប់ចោទមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះឡើយ។

- ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ក៏ដូចជារបាយការណ៍របស់សមត្ថកិច្ច អាចឲ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ហៅ ណុច ភេទស្រី អាយុ ២១ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

- វត្ថុចាប់យករួមមាន៖ ស្រោមសំបុត្របិទជិតពណ៌ លឿង ដែលមានសរសេរថា ក្រាម សថ្លា ទម្ងន់ ៤៨.៧៨ g (សែសិបប្រាំបី កណ្តក់សញ្ញា ចិតសិបប្រាំបី ក្រាម) (មេតំហ្វេតាមីន) ជារបស់ជនជាប់ចោទឈ្មោះ នាង (រត់គេចខ្លួន) និងចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌។ គប្បីសម្រេចរឹបអូសបំផ្លាញចោល ។

- តាមលទ្ធផលកោសលវិច័យលេខ ២៥៨០០/២០ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០២០ របស់មន្ទីរពិសោធន៍អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានសន្និដ្ឋានថា៖ សំណាកនៅក្នុងស្រោមសំបុត្រពណ៌សបិទជិតមានហត្ថលេខាគណៈកម្មការ, និងសរសេរឈ្មោះ នាង គេចខ្លួន ។ សំណាកជាប្រភេទក្រាមម្សៅថ្លា, ពណ៌ស ទម្ងន់ ០.៧៤៧១ g (សូន្យ កណ្តក់សញ្ញា ប្រាំពីរពាន់បួនរយចិតសិបមួយ ក្រាម), មានលទ្ធផល វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់ គឺ ៧៩.៩៩% ។

37/1

+សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬ ម៉ាទឹកកក) ដែលមានកម្រិតសុទ្ធ ៧៩.៩៩%។ ដូច្នេះបរិមាណធាតុសុទ្ធគឺ៖ $\frac{48.78g \times 79.99}{100} = 39.0191$ក្រាម។

- ជនជាប់ចោទមានគ្រឿងញៀន ដែលមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ជាប្រភេទក្រាមម្សៅ (ហៅក្រៅម៉ាទឹកកក ឬ អាយ) ហើយមានបរិមាណធាតុសុទ្ធសរុបគឺ: ៣៩.០១៩១ g (សាមសិបប្រាំបួន កណ្ដក់សញ្ញា សូន្យ មួយរយកៅសិបមួយ ក្រាម) ។

- ជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ហៅ ណុច បាននិយាយសំដីចុងក្រោយថា: សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឲ្យខ្លួន។

- មេធាវីការពារឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា: សូមតុលាការសម្រេចផ្ដល់ស្ថានសម្រាលទោសដល់កូនក្ដីរបស់ខ្លួនផង។

- តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា: សុំតម្កល់ការចោទប្រកាន់ទុកជាបានការដដែល។

- មានពិរុទ្ធភាពគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើឈ្មោះ [redacted] ស្រីនិត ភេទស្រី អាយុ ២៣ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច តាមបណ្ដោយផ្លូវលេខ ៧៩ អិម ស៊ី ក្បែរផ្សារពោធិ៍ញាណ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិ មាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

## ហេតុដូច្នេះសម្រេច

I- ផ្ដន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ហៅ ណុច ភេទស្រី អាយុ ២១ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) កំណត់រយៈពេល 06(ប្រាំមួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០,០០០,០០០(ដប់លាន)រៀល ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន "ចំនួន ៤៨.៧៨g" ប្រព្រឹត្តនៅចំណុចតាមបណ្ដោយផ្លូវលេខ ៧៩ អិម ស៊ី ក្បែរផ្សារពោធិ៍ញាណ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិ មាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

II-វត្ថុតាងចាប់យករួមមាន៖ ក្រាម សថ្លា ទម្ងន់ ៤៨.៧៨ g (សែសិបប្រាំបី កណ្ដក់សញ្ញា ចិតសិបប្រាំបី ក្រាម) រឹបអូសបំផ្លាញចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ហៅ ណុច និងប្រកាសជាសាធារណៈនៅ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០២១។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ សុក្រ ១២រោច ខែ ចេត្រ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]